ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងមុខងារសាធារណៈ
លេខ : ១៥៤០ មស. ស.ភរ

ថ្ងៃ ចន្ទ ៥ កើត ខែផល្គុន ឆ្នាំច សំរឹទ្ធិស័ក ព.ស.២៥៦២
រាជធានីភ្នំពេញ ថ្ងៃទី ២៥ ខែមីនា ឆ្នាំ២០១៩

## គោរពជូន

## ឯកឧត្តម លោកជំទាវ អភិបាលនៃគណៈអភិបាលរាជធានី ខេត្ត

**កម្មវត្ថុ ៖** ស្តីពីសេចក្តីជូនដំណឹងដល់មន្ត្រីរាជការគ្រប់រាជធានី ខេត្ត ចូលរួមប្រឡងគ្រួតពិនិត្យសមត្ថភាពដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលបន្តសម្រាប់ឆ្នាំ២០១៩ នៅសាលាភូមិន្ទរដ្ឋបាល។

សេចក្តីដូចមានចែងក្នុងកម្មវត្ថុខាងលើ ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ អភិបាល** មេត្តាជ្រាបថា នៅឆ្នាំ២០១៩នេះ សាលាភូមិន្ទរដ្ឋបាលនឹងរៀបចំបើកវគ្គបណ្តុះបណ្តាលបន្តសម្រាប់មន្ត្រីរាជការ ដែលរួមមានវគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ វគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាល វគ្គវិក្រឹត្យការមន្ត្រីមធ្យម និងវគ្គវិក្រឹត្យការមន្ត្រីក្រមការ។ វគ្គបណ្តុះបណ្តាលបន្តមានរយៈពេល៩ខែ ដែលក្នុងនោះរួមមានការសិក្សាទ្រឹស្តី ការអនុវត្តជាក់ស្តែង និងការអនុវត្តការងារសកម្មភាពសង្គម។ ដោយផ្អែកលើលក្ខខណ្ឌ និងស្ថានភាពជាក់ស្តែងសម្រាប់ឆ្នាំ២០១៩នេះ សាលាភូមិន្ទរដ្ឋបាលបានកំណត់យកការបណ្តុះបណ្តាលបន្តមន្ត្រីជាន់ខ្ពស់ចំនួន១៦០នាក់ (វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ចំនួន១២០នាក់ និងវគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាលចំនួន៤០នាក់) និងមន្ត្រីមធ្យមចំនួន៨០នាក់(វគ្គវិក្រឹត្យការមន្ត្រីមធ្យមចំនួន៤០នាក់ និងវគ្គវិក្រឹត្យការមន្ត្រីក្រមការចំនួន៤០នាក់)។ ក្នុងន័យនេះខ្ញុំសូមគោរពជម្រាបជូន **ឯកឧត្តម លោកជំទាវ អភិបាល** មេត្តាជ្រាបថា ការចុះឈ្មោះរបស់មន្ត្រីរាជការចូលរួមប្រឡងគ្រួតពិនិត្យសមត្ថភាពដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០១៩ នាពេលខាងមុខនេះ គឺមិនមានការកំណត់ចំនួននោះទេ។

លក្ខណៈវិនិច្ឆ័យរបស់មន្ត្រីរាជការ ដែលអាចចុះឈ្មោះប្រឡងគ្រួតពិនិត្យសមត្ថភាពគឺមានដូចខាងក្រោម៖

**១)វគ្គបណ្តុះបណ្តាលបន្តមន្ត្រីជាន់ខ្ពស់**

**ក)វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់**

- រដ្ឋបាលថ្នាក់ក្រោមជាតិ ៖ មន្ត្រីរាជការកំពុងកាន់តំណែងជាអភិបាលក្រុង ស្រុក ខណ្ឌ នាយករដ្ឋបាលសាលារាជធានី-ខេត្ត ប្រធានមន្ទីរជុំវិញរាជធានី-ខេត្ត ឬតំណែងប្រហាក់ប្រហែលឡើងទៅ(មិនមែនមន្ត្រីនយោបាយមានឋានៈស្មើ)
- មន្ត្រីរាជការខាងលើត្រូវមានអតីតភាពការងារយ៉ាងតិច៣ឆ្នាំ ក្នុងមុខងារសាធារណៈគិតចាប់ពីកាលបរិច្ឆេទចូលបម្រើការងារក្នុងមុខងារសាធារណៈ។

**ខ)វគ្គវិក្រឹត្យការមន្ត្រីគ្រប់គ្រងរដ្ឋបាល**

- រដ្ឋបាលថ្នាក់ក្រោមជាតិ ៖ មន្ត្រីរាជការស៊ីវិលក្របខណ្ឌ(ក)
- មន្ត្រីរាជការខាងលើត្រូវមានអតីតភាពការងារយ៉ាងតិច៣ឆ្នាំ ក្នុងមុខងារសាធារណៈគិតចាប់ពីកាលបរិច្ឆេទនៃការចូលបម្រើការងារក្នុងមុខងារសាធារណៈ។

ផ្លូវវត្តអង្គតាមិញ ភូមិគោកចំបក់ សង្កាត់ចោមចៅ ខណ្ឌពោធិ៍សែនជ័យ រាជធានីភ្នំពេញ ព្រះរាជាណាចក្រកម្ពុជា
ទូរស័ព្ទ/ទូរសារ : +៨៥៥-២៣-៨៦៦៥០១/+៨៥៥-២៣-៨៦៦៥០៥ | គេហទំព័រ : http://www.mcs.gov.kh

២)វគ្គបណ្តុះបណ្តាលបន្តមន្ត្រីមធ្យម

ក)វគ្គវិក្រឹត្យការមន្ត្រីមធ្យម

- រដ្ឋបាលថ្នាក់ក្រោមជាតិ ៖មន្ត្រីរាជការកំពុងកាន់ក្នុងតំណែងជាអភិបាលរងក្រុង ស្រុក ខណ្ឌ នាយករងរដ្ឋបាលសាលារាជធានី-ខេត្ត អនុប្រធានមន្ទីរជុំវិញរាជធានី-ខេត្ត នាយករដ្ឋបាលសាលាក្រុង ស្រុក ខណ្ឌ ឬមុខតំណែងប្រហាក់ប្រហែលចុះក្រោម(មិនមែនមន្ត្រីនយោបាយមាន ឋានៈស្មើ)
- មន្ត្រីរាជការខាងលើត្រូវមានអតីតភាពការងារយ៉ាងតិច២ឆ្នាំក្នុងមុខងារសាធារណៈគិតចាប់ពីកាលបរិច្ឆេទនៃការចូលបម្រើការងារក្នុងមុខងារសាធារណៈ។

ខ)វគ្គវិក្រឹត្យការមន្ត្រីក្រមការ

- រដ្ឋបាលថ្នាក់ក្រោមជាតិ ៖ មន្ត្រីរាជការស៊ីវិលក្របខណ្ឌ(ខ) ព្រមទាំងយោធិន ឬ មន្ត្រីនគរបាលជាតិមានឋានន្តរសក្តិក្រោមវរសេនីយ៍ឯក
- មន្ត្រីរាជការខាងលើ ត្រូវមានអតីតភាពការងារយ៉ាងតិច២ឆ្នាំ ក្នុងមុខងារសាធារណៈគិតចាប់ពីកាលបរិច្ឆេទនៃការចូលបម្រើការងារក្នុងមុខងារសាធារណៈ។

មន្ត្រីរាជការ ដែលមានគោលបំណងអភិវឌ្ឍសមត្ថភាពបន្ថែមអាចចូលរួមក្នុងការប្រឡងត្រួតពិនិត្យសមត្ថភាព ដើម្បីចូលរៀនវគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០១៩ ដោយត្រូវបំពេញបែបបទតាមប្រព័ន្ធOnlineលើគេហទំព័រសាលាភូមិន្ទរដ្ឋបាល sms.era.gov.kh និងត្រូវមានឯកសារភ្ជាប់ជាមួយដូចជា៖

១) ព្រះរាជក្រឹត្យ អនុក្រឹត្យ ឬប្រកាស បញ្ជាក់ពីការចូលបម្រើការងារក្នុងក្របខណ្ឌរដ្ឋ

២)ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស ដីកា ឬសេចក្តីសម្រេច បញ្ជាក់ពីការតែងតាំងក្នុងតំណែង(សម្រាប់វគ្គវិក្រឹត្យការមន្ត្រីជាន់ខ្ពស់ និងវគ្គវិក្រឹត្យការមន្ត្រីមធ្យម)

៣)ប្រវត្តិរូបសង្ខេបបញ្ជាក់ដោយនាយកដ្ឋាន ឬអង្គភាពទទួលបន្ទុកកិច្ចការបុគ្គលិករបស់ក្រសួង ស្ថាប័ន ឬប្រធានអង្គភាពគ្រប់គ្រងមន្ត្រីផ្ទាល់(អាចទាញយកតាមពីគេហទំព័រសាលាភូមិន្ទរដ្ឋបាល sms.era.gov.kh)

៤)លិខិតបង្ហាញហេតុ (Motivation Letter) របស់សាមីខ្លួន(អាចទាញយកតាមពីគេហទំព័រសាលាភូមិន្ទរដ្ឋបាល sms.era.gov.kh)

៥)សញ្ញាបត្រខ្ពស់ជាងគេ(ឧទាហរណ៍៖ សញ្ញាបត្របណ្ឌិត បរិញ្ញាបត្រជាន់ខ្ពស់ បរិញ្ញាបត្រ ឬបរិញ្ញាបត្ររង)

ខ្ញុំសូមជម្រាបជូន **ឯកឧត្តម លោកជំទាវ អភិបាល** មេត្តាជ្រាបថាមន្ត្រីរាជការ ដែលមានបំណងអភិវឌ្ឍសមត្ថភាពក្នុងក្របខណ្ឌនៃវគ្គបណ្តុះបណ្តាលបន្តឆ្នាំ២០១៩ នៅសាលាភូមិន្ទរដ្ឋបាលនឹងត្រូវអនុញ្ញាតឲ្យបំពេញបែបបទតាមប្រព័ន្ធ Online ចាប់ពី**ថ្ងៃទី២០ ខែមីនា ឆ្នាំ២០១៩ រហូតដល់ថ្ងៃទី៣០ ខែមេសា ឆ្នាំ២០១៩**។ បន្ទាប់ពីមន្ត្រីរាជការបានប្រឡងជាប់ជាស្ថាពរ សាលាភូមិន្ទរដ្ឋបាលនឹងរៀបចំលិខិតស្នើសុំការសម្រេចជាគោលការណ៍ឯកភាពពី **ឯកឧត្តម លោកជំទាវ អភិបាល** ដើម្បីផ្តល់ការអនុញ្ញាតឲ្យសាមីខ្លួនមកទទួលការបណ្តុះបណ្តាលក្នុងរយៈពេល៩ខែ។

សេចក្តីដូចបានជម្រាបជូនខាងលើ សូម **ឯកឧត្តម លោកជំទាវ អភិបាល** មេត្តាជ្រាប និងមានចំណាត់ការតាមការគួរ។

សូម **ឯកឧត្តម លោកជំទាវ អភិបាល** ទទួលនូវការគោរពរាប់អានដ៏ស្មោះស្ម័គ្រពីខ្ញុំ។

**រដ្ឋមន្ត្រី**

ពេជ្រ ប៊ុនធិន

**ចម្លងជូន៖**

-ខុទ្ទកាល័យសម្តេចតេជោ នាយករដ្ឋមន្ត្រី

-ខុទ្ទកាល័យសម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី

-សមាជិកក្រុមប្រឹក្សាសាលាភូមិន្ទរដ្ឋបាល

-ឯកសារ-កាលប្បវត្តិ

*សម្រាប់ព័ត៌មានបន្ថែម* -០៧៧ ២៨៨ ៩៨៨, ០១២ ៧៩៧ ៧៨៩

*សូមមេត្តាទំនាក់ទំនង៖* -០៨៩ ៨៤៥ ៥៥៥, ០៨៦ ៧៩ ៦៩ ៦៦១

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួង.....................................
អង្គភាព.....................................

4 x 6

# ប្រវត្តិរូបសង្ខេប
# មន្ត្រីរាជការស្នើសុំចូលរួមប្រឡងចូលសិក្សានៅសាលាភូមិន្ទរដ្ឋបាល

**ព័ត៌មានផ្ទាល់ខ្លួន**

- គោត្តនាម និងនាម.................................................... អក្សរឡាតាំង.......................................................... ភេទ : ស្រី☐ ប្រុស☐
- កើតថ្ងៃទី................ ខែ..................... ឆ្នាំ................ សញ្ជាតិ............................ កើតនៅភូមិ.................................................. ឃុំ (សង្កាត់) .......................................... ស្រុក (ខណ្ឌ)............................... ខេត្ត (រាជធានី )..................................................
- លេខទូរស័ព្ទផ្ទាល់ខ្លួន.................................. លេខទូរស័ព្ទក្នុងករណីបន្ទាន់............................... អ៊ីម៉ែល:............................................ និងលេខទូរស័ព្ទរបស់អង្គភាព ឬនាយកដ្ឋានបុគ្គលិក.................................................. ឬ.........................................................

**អាសយដ្ឋានបច្ចុប្បន្ន**....................................................................................................................................

**ស្ថានភាពបច្ចុប្បន្ន**

- ធ្វើការនៅក្រសួង/ ស្ថាប័ន/ អង្គភាព.................................................. មុខតំណែងជា........................................... ក្របខណ្ឌ និង ឋានន្តរសក្តិ........................................ អត្តលេខមន្ត្រីរាជការ.................................. លេខអត្តសញ្ញាណប័ណ្ណ...........................................

**ភាសាបរទេស**...............................................................................................................................................

**កម្រិតវប្បធម៌ទូទៅ**................................ គ្រឹះស្ថានសិក្សា.................................... ទីកន្លែងសិក្សា.............................. សញ្ញាប័ត្រដែលទទួលបាន .................................. ថ្ងៃខែឆ្នាំចូលសិក្សា........................................... ថ្ងៃខែឆ្នាំបញ្ចប់ការសិក្សា.....................................

**កម្រិតបណ្តុះបណ្តាលចុងក្រោយ**.................................................. គ្រឹះស្ថានសិក្សា.................................................. ទីកន្លែងសិក្សា .............................. សញ្ញាប័ត្រដែលទទួលបាន............................. ថ្ងៃខែឆ្នាំចូលសិក្សា...................... ថ្ងៃខែឆ្នាំបញ្ចប់ការសិក្សា.......................

**ព័ត៌មានពាក់ព័ន្ធការងារ**

| ថ្ងៃខែឆ្នាំចូលបំពេញការងារ | ថ្ងៃខែឆ្នាំបញ្ចប់ការងារ | ក្រសួង-ស្ថាប័ន | នាយកដ្ឋាន ឬអង្គភាព ឬមន្ទីរ | ការិយាល័យ | មុខតំណែង |
|---|---|---|---|---|---|
| | | | | | |
| | | | | | |
| | | | | | |
| | | | | | |

ខ្ញុំ/នាងខ្ញុំសូមធានាទទួលខុសត្រូវចំពោះមុខច្បាប់ថា ព័ត៌មានបំពេញខាងលើនេះ ពិតជាត្រឹមត្រូវប្រាកដមែន។

បានឃើញ និងបញ្ជាក់ថា
ព័ត៌មានដែលលោក/ លោកស្រី..............................................
បានអះអាងខាងលើពិតជាត្រឹមត្រូវប្រាកដមែន។
ធ្វើនៅ...................... ថ្ងៃទី............. ខែ............... ឆ្នាំ.............
ហត្ថលេខា (ប្រធានអង្គភាព)

ធ្វើនៅ.................... ថ្ងៃទី............ ខែ............ ឆ្នាំ២០......
ហត្ថលេខា (សាមីខ្លួន)

ឈ្មោះ..............................................

ឈ្មោះ.............................................
មុខតំណែង............................................................................
និងទូរស័ព្ទ.......................................... អ៊ីម៉ែល..........................................

បញ្ជាក់៖ - បេក្ខជនត្រូវភ្ជាប់មកជាមួយនូវរូបថតថ្មី ៤×៦ ចំនួន ៥សន្លឹក និង៣×៤ ចំនួន ៥សន្លឹក។
- ប្រធានអង្គភាពសំដៅដល់មន្ត្រីរាជការដែលមានឋានានុក្រមខ្ពស់មន្ត្រីរាជការដែលស្នើសុំប្រឡងប្រជែងចូលសិក្សានៅ ស.ភ.រ។

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

# លិខិតបញ្ជាក់ហេតុ
# មន្ត្រីរាជការស្នើសុំចូលរួមប្រឡងចូលសិក្សានៅសាលាភូមិន្ទរដ្ឋបាល

**ព័ត៌មានអំពីការងារ និងបទពិសោធន៍**

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

.................................................................................................................................................។

**មូលហេតុ និងគោលបំណងនៃការស្នើសុំ**

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

.................................................................................................................................................។

**ការរំពឹងទុកអំពីការទទួលបានអត្ថប្រយោជន៍នៃការសិក្សានៅសាលាភូមិន្ទរដ្ឋបាល**

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

..................................................................................................................................................

.................................................................................................................................................។

ធ្វើនៅ....................ថ្ងៃទី............ខែ.............ឆ្នាំ២០.......

ហត្ថលេខា (សាមីខ្លួន)

ឈ្មោះ.............................................